ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណីលេខ១២០២
ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧
សាលក្រមលេខ ៧៨ (ឈ)
ថ្ងៃទី២៥/១០/២០១៨

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨

## សមាសភាពជំនុំជម្រះ

- លោក **សាយ សម្ផស្សសេរី** ជាចៅក្រមជំនុំជម្រះ
- លោក [redacted] ជាក្រឡាបញ្ជីសវនាការ

-ដើមចោទ ឈ្មោះ [redacted] ឡាយខាន់ ភេទស្រី កើតឆ្នាំ១៩៥៤ មានអាសយដ្ឋាន [redacted]
មានអ្នកតំណាងដោយអាណត្តិ [redacted]

-ចុងចម្លើយ ឈ្មោះ [redacted] សូនី ភេទប្រុស អាយុ៤៣ឆ្នាំ និងឈ្មោះ [redacted] ស៊ីណាត ភេទស្រី អាយុ៤៤ឆ្នាំ មានអាសយដ្ឋាន [redacted]
មានអ្នកតំណាងដោយអាណត្តិ [redacted]

## អង្គហេតុ និង ចំណុចវិវាទ

១. សាលក្រមដែលទាមទារដោយដើមចោទ

ប្ដឹងសុំឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ស៊ីណាត និងឈ្មោះ [redacted] សូនី សងប្រាក់ដើមចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។

២.បង់ការប្រាក់ចំនួន ១,៥% (មួយក្បៀសប្រាំ) ភាគរយ ក្នុងមួយខែ លើប្រាក់ដើមចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន។

៣.បង្គាប់ឱ្យចុងចម្លើយបង់ការខាតបង់ពេលវេលា និងជម្ងឺចិត្តចំនួនចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក មកឱ្យដើមចោទ

៤.សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន

៥.សុំឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្ដី

២. ការពន្យល់ត្រួសៗអំពីរឿងក្ដី

រឿងក្ដីនេះ ជារឿងក្ដីដែលដើមចោទប្ដឹងទាមទារប្រាក់ ពីសហចុងចម្លើយឈ្មោះ [redacted] សូនី និងប្រពន្ធឈ្មោះ [redacted] ស៊ីណាត ដោយសារ កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ដោយចុះកិច្ចសន្យាខ្ចីប្រាក់ជាលាយលក្ខណ៍អក្សរ។ ក្នុងកិច្ចសន្យានេះ ចុងចម្លើយត្រូវបង់ការប្រាក់ចំនួន ១,៥%(មួយក្បៀសប្រាំ)ភាគរយ ស្មើនឹងប្រាក់ចំនួន ៣០០ (បីរយ)ដុល្លារអាមេរិក ក្នុងមួយខែ និងត្រូវសងប្រាក់ដើមគ្រប់ចំនួនវិញក្នុងអំឡុងពេល១២ខែ។ ក្នុងការខ្ចីប្រាក់នេះ ចុងចម្លើយបានដាក់បញ្ចាំផ្ទះ និងដី

ដែលមានបណ្តោយប្រវែង ៣៥ម៉ែត្រ ទទឹងប្រវែង ១៤ម៉ែត្រ ស្ថិតក្នុងភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

ដល់កាលកំណត់សងប្រាក់ដើម (ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥) ចុងចម្លើយមិនបានសងប្រាក់ដើមទេ គឺសុំខ្ចីមួយរយៈពេលទៀត ដោយសុំបន្តបង់ការប្រាក់តាមកិច្ចសន្យា។ លុះដល់ថ្ងៃទី ១០ខែធ្នូ ឆ្នាំ២០១៥ ចុងចម្លើយឈប់បង់ការប្រាក់រហូតដល់សព្វថ្ងៃ ទោះបីជាដើមចោទបានធ្វើលិខិតដាស់តឿន និងជូនដំណឹងឱ្យសងប្រាក់ក៏ដោយ ក៏ចុងចម្លើយមិនព្រមសងប្រាក់ដើម និងបង់ការប្រាក់ឡើយ។

**៣. ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

៣.១. ចំណុចវិវាទ:

-ប្រាក់ដើម

-ការប្រាក់

៣.២. ចំណុចគ្មានវិវាទ:

ចុងចម្លើយទទួលស្គាល់ថាខ្លួនពិតជាបានផ្តិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ប្រាកដមែន។

**៤. ការអះអាងរបស់គូភាគី**

**៤.១. ការអះអាងរបស់ដើមចោទ**

-មេធាវីតំណាងឱ្យដើមចោទ លោកស្រី [redacted] អះអាងនៅក្នុងនីតិវិធីត្រៀមថា ខ្លួនសូមរក្សាសេចក្តីថ្លែងការណ៍ និងការទាមទារដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ ដោយៈ

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ស៊ីណាត និងឈ្មោះ ឯម សូនី សងប្រាក់ដើមចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន។

២.បង់ការប្រាក់ចំនួន ១,៥% ក្នុងមួយខែ លើប្រាក់ដើមចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦ រហូតដល់សងប្រាក់ដើម គ្រប់ចំនួន។

៣.បង្គាប់ឱ្យសហចុងចម្លើយបង់ការខាតបង់ពេលវេលា និងជម្ងឺចិត្តចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក

៤.សុំប្រកាសអនុវត្តសាលក្រមជាបណ្តោះអាសន្ន

៥.សុំឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី

កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ដោយចុះកិច្ចសន្យាខ្ចីប្រាក់ជាលាយលក្ខណ៍អក្សរ។ ក្នុងកិច្ចសន្យានេះ ចុងចម្លើយត្រូវបង់ការប្រាក់ចំនួន ១,៥% (មួយក្បៀសប្រាំ) ភាគរយ ស្មើនឹងប្រាក់ចំនួន ៣០០ (បីរយ) ដុល្លារអាមេរិក ក្នុងមួយខែ និងត្រូវសងប្រាក់ដើមគ្រប់ចំនួនវិញក្នុងអំឡុងពេល១២ខែ។ ក្នុងការខ្ចីប្រាក់នេះ ចុងចម្លើយបានដាក់បញ្ចាំផ្ទះ និងដីដែលមានបណ្តោយប្រវែង ៣៥ម៉ែត្រ ទទឹងប្រវែង ១៤ម៉ែត្រ ស្ថិតក្នុង[redacted]មានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងដីឈ្មោះ [redacted]ភា ខាងកើតទល់នឹងផ្លូវរទេះ ខាងលិចទល់នឹងផ្លូវលំ ហើយដោយមានលិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីលេខ១៥០/១៤ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤ របស់មេឃុំវិហារសួគ៌។

Scanned with CamScanner

នៅពេលដល់កាលកំណត់សងប្រាក់ដើម (ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥) ចុងចម្លើយមិនបានសងប្រាក់ដើមទេ គឺសុំខ្ចីមួយរយៈពេលទៀត ដោយសុំបន្តបង់ការប្រាក់តាមកិច្ចសន្យា។ លុះដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ ចុងចម្លើយឈប់បង់ការប្រាក់រហូតដល់សព្វថ្ងៃ ទោះបីជាដើមចោទបានធ្វើលិខិតដាស់តឿន និងជូនដំណឹងអំពីការសងប្រាក់ជំពាក់ដល់ចុងចម្លើយចំនួនពីរលើក(លើកទី១នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ និងលើកទី២ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧) ក៏ចុងចម្លើយមិនព្រមសងប្រាក់ដើម និងបង់ការប្រាក់ឡើយ។

-មេធាវីដើមចោទលោកស្រី [redacted] អះអាងតបថា សូមច្រានចោលការអះអាងរបស់ចុងចម្លើយ ដោយហេតុថា កិច្ចសន្យាខ្ចីប្រាក់នោះ គឺឈ្មោះ [redacted] សុវនី និងឈ្មោះ [redacted] ស៊ីណាត ជាអ្នកផ្តិតមេដៃខ្ចី និងបានផ្តិតមេដៃនៅចំពោះមុខមេភូមិស្វាយមាស ដើម្បីធ្វើការបញ្ជាក់ថា ចុងចម្លើយបានខ្ចីប្រាក់ចំនួន ២០០០០(ពីរម៉ឺន)ដុល្លារ ដោយមានដាក់បញ្ចាំដី និងផ្ទះ ដែលមានពាក្យស្នើសុំកាន់កាប់ដីធ្លីគឺពុំមានការចូលរួមខ្ចីពីឈ្មោះ [redacted] ម៉ាទីណេ នោះទេ ។ ហើយចំពោះការលើកឡើងថា កូនក្តីរបស់ខ្លួនបានទទួលការប្រាក់ពីចុងចម្លើយលើប្រាក់ដើមតែចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ក៏មិនពិតប្រាកដដែរ គឺចុងចម្លើយបានបង់ការប្រាក់ចំនួន ៣០០ (បីរយ) ដុល្លារ ជារៀងរាល់ខែឱ្យមកកូនក្តីខ្លួនរហូតដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦ ទើបចុងចម្លើយអាក់ខានបង់ការប្រាក់មកឱ្យកូនក្តីខ្លួនរហូតដល់បច្ចុប្បន្ន ហើយកូនក្តីខ្លួនបានធ្វើលិខិតដាស់តឿន និងជូនដំណឹងអំពីការសងប្រាក់ជំពាក់ចំនួនពីរដង គឺបានបញ្ជាក់លើលិខិតដាស់តឿននៅចំនួនទឹកប្រាក់ដើមដែលនៅជំពាក់ចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។

-មេធាវីដើមចោទ អះអាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ថា កូនក្តីខ្លួនសុំទាមទារដដែល តែកែប្រែត្រង់ពីប្រាក់ដើមចំនួន ២០,០០០ ដុល្លារអាមេរិក មកចំនួន ១៥,០០០ ដុល្លារអាមេរិក ការប្រាក់ដដែល និងជម្ងឺចិត្តចំនួន ៥,០០០ ដុល្លារអាមេរិក សុំប្រកាសអនុវត្តសាលក្រមជាបណ្តោះអាសន្ន។ ហើយការសុំអនុគ្រោះវិញ បើសុំអនុគ្រោះសំណងជម្ងឺចិត្តអាចលើកលែងបាន បើចំពោះការប្រាក់មិនអាចទេ ខ្ចីយូរហើយ ព្រោះខ្លួនបានដាស់តឿនគាត់យូរហើយ ហើយប្រពន្ធគាត់ថាប្តឹងដល់ណាដល់ទៅ។ ហើយដំណើរការរឿងក្តីច្រើនហើយ ហើយមានការចុះដល់ផ្ទះរបស់គាត់ទៀត។

### ៤.២. ការអះអាងរបស់ចុងចម្លើយ

-ចុងចម្លើយឈ្មោះ [redacted] សុវនី អះអាងតបក្នុងនីតិវិធីត្រៀមថា ខ្លួនសូមទទួលស្គាល់បំណុលតែចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារ ទេ ក្រៅពីនេះខ្លួនមិនទទួលស្គាល់ទេ និងសុំសងក្នុងមួយខែចំនួន ៥០ (ហាសិប) ដុល្លារ ពីព្រោះចំពោះលុយដើម ៥,០០០ (ប្រាំពាន់) ដុល្លារ ទៀតអោយទៅឈ្មោះ [redacted] ម៉ាទីណេ ភេទប្រុស [redacted] ដែរ ហើយដើមចោទក៏ធ្លាប់បានទទួលការប្រាក់លើប្រាក់ចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក ពីឈ្មោះ [redacted] ម៉ាទីណេ ដែរ ហើយម្តាយក្មេករបស់ឈ្មោះ [redacted] ម៉ាទីណេ ឈ្មោះ [redacted] ណៃកយ ភេទស្រី [redacted] ជាសាក្សីដឹងឮដែរ។

-មេធាវីចុងចម្លើយអះអាងបន្ថែមថា ដោយសារដើមចោទធ្លាប់ទទួលស្គាល់ការបង់ការប្រាក់លើប្រាក់ដើមតែចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារ ពីកូនក្តីខ្លួនឈ្មោះ [redacted] សុវនី ឯប្រាក់ចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារ ទៀត ដើមចោទក៏ធ្លាប់បានទទួលការប្រាក់ពីឈ្មោះ [redacted] ម៉ាទីណេ ដូចការថ្លែងការណ៍របស់កូនក្តីខ្លួន មានន័យថា ដើមចោទធ្លាប់បានទទួលស្គាល់ និងអនុវត្តរួចហើយលើបំណុលចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារ ចំពោះកូនក្តីខ្លួនតែប៉ុណ្ណោះ។ ដូចនេះក្នុងនាមមេធាវីតំណាងឱ្យចុងចម្លើយ សូមឱ្យដើមចោទធ្វើការទាមទារប្រាក់ចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារ ពីឈ្មោះ [redacted] ម៉ាទីណេ។

Scanned with CamScanner

-ចុងចម្លើយឈ្មោះ [redacted] សូនី អះអាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា ខ្លួនទទួលស្គាល់ខ្ចីប្រាក់ចំនួន ១៥,០០០ ដុល្លារអាមេរិក ការប្រាក់ និងប្រាក់ពិន័យ និងបានដាក់បញ្ចាំលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីពិតប្រាកដមែន។ កាលផ្តិតមេដៃហ្នឹង ប្រពន្ធខ្លួនអត់នៅទេ ប្អូនថ្លៃខ្លួនផ្តិតមេដៃជំនួស តែប្រពន្ធខ្លួនក៏ដឹងរឿងខ្ចីលុយហ្នឹងដែរ។

**សំអាងហេតុ**

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យឯកសារនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

-មេធាវី [redacted] តំណាងឱ្យដើមចោទ បានអះអាងថា កូនក្តីខ្លួនសុំទាមទារដដែល តែកែប្រែត្រង់ពីប្រាក់ដើមចំនួន ២០,០០០ ដុល្លារ មកចំនួន ១៥,០០០ ដុល្លារ ការប្រាក់ដដែល និងជម្ងឺចិត្តចំនួន ៥,០០០ ដុល្លារ សុំប្រកាសអនុវត្តសាលក្រមជាបណ្តោះអាសន្ន។

-ចុងចម្លើយឈ្មោះ [redacted] សូនី អះអាងថា ខ្លួនទទួលស្គាល់ខ្ចីប្រាក់ចំនួន ១៥,០០០ ដុល្លារ ការប្រាក់ និងប្រាក់ពិន័យ និងបានដាក់បញ្ចាំលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីពិតប្រាកដមែន។ ប្រពន្ធខ្លួនក៏ដឹងរឿងខ្ចីលុយរបស់ដើមចោទដែរ។ ខ្លួនជាកងកម្លាំងប្រដាប់អាវុធ មានលទ្ធភាពអាចសងបានតែ ១០០ ដុល្លារក្នុងមួយខែប៉ុណ្ណោះ។

- យោងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ រវាងឈ្មោះ លី ឡាយខាន់ ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] សូនី ឈ្មោះ [redacted] ស៊ីណាត បញ្ជាក់ថា ឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] ស៊ីណាត ពិតជាបានខ្ចីប្រាក់ឈ្មោះ [redacted] ឡាយខាន់ ចំនួន ២០,០០០ ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១,៥ ភាគរយក្នុងមួយខែ ដោយបានដាក់បញ្ចាំដី និងផ្ទះ ដែលមានទំហំបណ្តោយ ៣៥ ម៉ែត្រ ទទឹង ១៤ ម៉ែត្រ ស្ថិតនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង [redacted] ភា ខាងកើតទល់នឹងផ្លូវរទេះ និងខាងលិចទល់នឹងផ្លូវលំ ពិតប្រាកដមែន ហើយកិច្ចសន្យាបានដល់កំណត់ថ្ងៃសងហើយ ដែលអាចបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិលើបំណុល ដែលដើមចោទមានចំពោះចុងចម្លើយឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] ស៊ីណាត។

-យោងលិខិតបញ្ជាក់របស់លោក [redacted] មេភូមិស្វាយមាស បញ្ជាក់ថា ឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] ស៊ីណាត ពិតជាបានខ្ចីប្រាក់ចំនួន ២០,០០០ ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១,៥ ភាគរយក្នុងមួយខែ ពីឈ្មោះ [redacted] ឡាយខាន់ ដោយបានដាក់បញ្ចាំដី និងផ្ទះ ដែលមានទំហំបណ្តោយ ៣៥ ម៉ែត្រ ទទឹង ១៤ ម៉ែត្រ ស្ថិតនៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង [redacted] ភា ខាងកើតទល់នឹងផ្លូវរទេះ និងខាងលិចទល់នឹងផ្លូវលំ ពិតប្រាកដមែន។

-យោងលិខិតដាស់តឿន និងជូនដំណឹងអំពីការសងប្រាក់ជំពាក់ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ និងលិខិតដាស់តឿន និងជូនដំណឹងជាលើកចុងក្រោយអំពីការសងប្រាក់ជំពាក់ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ ពិតជាបានដាស់តឿនឱ្យចុងចម្លើយទៅសងប្រាក់ពិតមែន។

-ដើមចោទទាមទារប្រាក់ដើមចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងការប្រាក់ ១,៥ (មួយក្បៀសប្រាំ) ភាគរយ ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃឈប់បង់ការប្រាក់ គឺថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦ រហូតសងប្រាក់ដើមអស់ពីចុងចម្លើយឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] ស៊ីណាត ហើយចុងចម្លើយឈ្មោះ [redacted] សូនី ក៏បានទទួលស្គាល់ដែរ គប្បីសាលាដំបូងសម្រេចតាមការទាមទារនេះ ដោយសាលក្រមចំពោះមុខចុងចម្លើយឈ្មោះ [redacted] សូនី និងកំបាំងមុខចុងចម្លើយឈ្មោះ [redacted] ស៊ីណាត យោងតាមមាត្រា ៥៧៨, ៥៧៩, ៥៨៣, ៥៨៥, ៥៩១, ៥៩៤ នៃក្រមរដ្ឋប្បវេណី និងមាត្រា ២០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

Scanned with CamScanner

-ដើមចោទទាមទារឱ្យសហចុងចម្លើយឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] ស៊ីណាត សងប្រាក់ជំងឺចិត្ត និងសំណងនៃការខូចខាតពេលវេលា សរុបចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក សាលាដំបូងគប្បីសម្រេចតាមភាពជាក់ស្តែង។

-ដើមចោទសុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន ឃើញថា កម្មវត្ថុនៃការប្តឹងទាមទារជាសិទ្ធិលើទ្រព្យសម្បត្តិ ហើយដើម្បីបង្ការកុំឱ្យការប្រាក់នេះចេះតែកើនឡើង ដែលជាបន្ទុករបស់ចុងចម្លើយ គប្បីតុលាការពិចារណាសម្រេចអនុវត្តជាបណ្តោះអាសន្ន ត្រង់ប្រាក់ដើមចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក យោងតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-ដើមចោទឱ្យចុងចម្លើយទទួលបន្ទុកនូវប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី សាលាដំបូងគប្បីសម្រេចឱ្យចុងចម្លើយ ទទួលបន្ទុកប្រាក់ប្រដាប់ក្តី យោងតាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១.ឱ្យចុងចម្លើយឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] ស៊ីណាត សងប្រាក់ដើមចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ឱ្យដើមចោទឈ្មោះ លី ឡាយខាន់។

២.ឱ្យសហចុងចម្លើយបង់ការប្រាក់ ចំនួន ១,៥% (មួយក្បៀសប្រាំ) ភាគរយ ក្នុងមួយខែលើប្រាក់ដើមចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក គិតពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦ មកឱ្យដើមចោទ រហូតដល់ថ្ងៃសងប្រាក់ដើមរួច។

៣.ឱ្យចុងចម្លើយសងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា ចំណាយផ្សេងៗ រួមទាំងថ្លៃសេវាកម្មច្បាប់សរុប ចំនួន ៤,០០០,០០០ (បួនលាន) រៀល ឱ្យមកដើមចោទ។ ការទាមទារលើសពីនេះត្រូវបដិសេធចោល។

៤.សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាននូវចំណុចទី១ នៃសេចក្តីសម្រេច។

៥.ឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកនូវប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី។

-ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅ [illegible] ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]